00637129

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

D 427/5/10

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ ១៥២)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១១

---

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ**

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew CAYLEY
យ៉េត ចរិយា
Villiam SMITH
សេង ប៊ុនឃាង

**<u>ជនត្រូវចោទ</u>**
អៀង សារី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 01 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ឡោ ជុនធី

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Philippe CANONNE
Elizabeth RABESANDRATANA
Mahdev MOHAN
Olivier BAHOUGNE
Silke STUDZINSKY
Annie DELAHAIE
Fabienne TRUSSES-NAPROUS

ស៊ីន សុវន

Patrick BEAUDOIN
Marie GUIRAUD
Lyma NGUYEN

ពេជ អង្គ

ជេត វណ្ណលី

Laure DESFORGES
Isabelle DURAND
Francoise GAUTRY
Christine MARTINEAU
Pascal AUBOIN
Ferdinand DJAMMEN-NZEPA
Emmanuel ALTIT
Emmanuel JACOMY
Julien RIVET
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ

វ៉ែន ពៅ

**សហមេធាវីការពារជនត្រូវចោទ**

អាង ឧត្តម

Michael G. KARNAVAS

អ.វ.ត.ក * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00637131



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ” (“បណ្តឹងឧទ្ធរណ៍”)[១]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានដាក់ដីកាដំណោះស្រាយ[២] ដែលបានធ្វើការជូនដំណឹងដល់ភាគីនានានៅក្នុងថ្ងៃដដែល។

២. នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ សហមេធាវីការពារក្តីជនជាប់ចោទបានដាក់បណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍ត្រូវបានជូនដំណឹងដល់ភាគីនានាជាភាសាអង់គ្លេស និងជាភាសាខ្មែរ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០។

៣. នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ សហមេធាវីការពារក្តីជនជាប់ចោទបានដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសមួយទៀតប្រឆាំងនឹងដីកាដំណោះស្រាយ ស្របតាមការពន្យារពេលដែលត្រូវបានអនុញ្ញាតដោយអង្គបុរេជំនុំជម្រះ (“បណ្តឹងឧទ្ធរណ៍អំពីយុត្តាធិការ”)[៣]។

៤. នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ “សេចក្តីសង្កេតបឋមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែករបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងយុត្តាធិការ” (សេចក្តីសង្កេតបឋម”)[៤]។

---

[១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/5/1។

[២] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427។

[៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6។

[៤] សេចក្តីសង្កេតបឋមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែករបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងយុត្តាធិការ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/7 និង D427/5/2។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៥. នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ សហមេធាវីជនជាប់ចោទបានដាក់ចម្លើយតបទៅនឹងសេចក្តីអង្កេតបឋមរបស់សហព្រះរាជអាជ្ញា[៥]។

៦. នៅថ្ងៃដដែល អង្គបុរេជំនុំជម្រះបានជូនដំណឹងអំពីសេចក្តីសម្រេចលើសេចក្តីអង្កេតបឋមរបស់សហព្រះរាជអាជ្ញា[៦] ដោយបានបញ្ជាក់អំពីការទទួលយកការដាក់បណ្តឹងឧទ្ធរណ៍ និងការដាក់បណ្តឹងឧទ្ធរណ៍អំពីយុត្តាធិការ និងបានបង្គាប់ឲ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នា។

៧. នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ("ចម្លើយតប")[៧]។ ចម្លើយតបត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០។

៨. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នោះទេ។

៩. នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ សហមេធាវីការពារក្តីជនជាប់ចោទបានដាក់សំណើសុំព័ត៌មានពាក់ព័ន្ធនឹងបញ្ហាថាតើនឹងមានសវនាការដេញដោលផ្ទាល់មាត់ដែរឬទេ។ សំណើសុំនេះត្រូវបានជូនដំណឹងដល់ភាគីនានានៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០។

១០. នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញដីកាកំណត់កាលបរិច្ឆេទសវនាការ

---

[៥] ចម្លើយតបរបស់ អៀង សារី ទៅនឹងការអង្កេតបឋមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នារបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងយុត្តាធិការ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/5/3។

[៦] សេចក្តីសម្រេចលើសេចក្តីសង្កេតបឋមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែករបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងយុត្តាធិការ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/5/4។

[៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/5/5 ("ចម្លើយតប")។

ដោយកំណត់កាលបរិច្ឆេទសវនាការដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០[៨]។

១១. នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០ សហមេធាវីការពារក្តីជនជាប់ចោទបានដាក់សំណើសុំអនុញ្ញាតិដើម្បីឆ្លើយតបជាលាយលក្ខណ៍អក្សរជំនួសឲ្យសវនាការដេញដោលផ្ទាល់មាត់ និងចម្លើយតបចំពោះការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយសម្រេចបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ន ("សំណើ និងចម្លើយតប")[៩]។

១២. នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានជូនដំណឹងអំពីដីកាសម្រេចលុបចោលសវនាការដើម្បីលុបចោលសវនាការដេញដោលផ្ទាល់មាត់ដែលបានកំណត់ធ្វើនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០។ អង្គបុរេជំនុំជម្រះបានទទួលយកការដាក់ឯកសារសំណើ និងចម្លើយតប និងបានបង្គាប់ថា បណ្តឹងឧទ្ធរណ៍នឹងត្រូវសម្រេចដោយផ្អែកតែលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ[១០]។

១៣. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានជូនដំណឹងអំពីសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះ-ស្រាយ[១១]។ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន និងបានបដិសេធចោលបណ្តឹងឧទ្ធរណ៍ ដោយបង្ហាញថា សាលដីកាដែលមានសំអាងហេតុចំពោះបណ្តឹងឧទ្ធរណ៍នេះ នឹងចេញទៅតាមវេលាកំណត់សម្រេច។

១៤. តាមរយៈនេះ អង្គបុរេជំនុំជម្រះផ្តល់នូវសំអាងហេតុសម្រាប់សាលដីការបស់ខ្លួន។

---

[៨] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០, D427/5/6។

[៩] សំណើសុំអនុញ្ញាតដើម្បីឆ្លើយតបជាលាយលក្ខណ៍អក្សរ ជំនួសឲ្យសវនាការដេញដោលផ្ទាល់មាត់ និងចម្លើយតបចំពោះការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយសម្រេចបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១០ ឯកសារ D427/5/7។

[១០] ដីកាសម្រេចលុបចោលសវនាការ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០ ឯកសារ D427/5/8។

[១១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/5/9។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

## II. ភាពអាចទទួលយកបាន

១៥. ដីកាដំណោះស្រាយត្រូវបានជូនដំណឹងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។ សហមេធាវីការពារក្តីជនជាប់ចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ ហើយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ បានដាក់បណ្តឹងឧទ្ធរណ៍ នៅក្នុងរយៈពេលកំណត់តាមការពន្យារពេលដោយសារតែទឹកលិចនៅតុលាការ។

១៦. ជនជាប់ចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន[១២]។ នៅក្នុងសេចក្តីសម្រេចលើសេចក្តីអង្កេតបឋមរបស់សហព្រះរាជអាជ្ញា[១៣] អង្គបុរេជំនុំជម្រះបានបញ្ជាក់អំពីការទទួលយកការដាក់ឯកសារបណ្តឹងឧទ្ធរណ៍ និងការដាក់ឯកសារបណ្តឹងឧទ្ធរណ៍អំពីយុត្តាធិការ ដោយឡែកពីគ្នា ដោយបានធ្វើការពិចារណាលើបញ្ហា "បណ្តឹងឧទ្ធរណ៍ទាំងនេះមានកម្មវត្ថុផ្សេងពីគ្នា និងដោយសារថា ជាផលវិបាកដំណាក់កាលនីតិវិធីផ្សេងៗពីគ្នា អាចត្រូវបានយកមកអនុវត្ត នៅពេលណាដែលចាំបាច់"[១៤]។

១៧. ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។

## III. ច្បាប់ជាធរមាន

១៨. សេចក្តីយោងធ្វើឡើងផ្អែកលើវិធាន ៦៣ និងវិធាន ៦៨ នៃវិធានផ្ទៃក្នុង។

---

[១២] វិធាន ៦៣(៤), ៧៤(៣)(ច) នៃវិធានផ្ទៃក្នុង។

[១៣] សេចក្តីសម្រេចលើសេចក្តីសង្កេតបឋមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែករបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយស្តីពីការឃុំខ្លួនបណ្តោះអាសន្ននិងបញ្ហាយុត្តាធិការ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/5/4។

[១៤] សេចក្តីសម្រេចលើសេចក្តីសង្កេតបឋមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែករបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយស្តីពីការឃុំខ្លួនបណ្តោះអាសន្ននិងបញ្ហាយុត្តាធិការ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/5/4 កថាខណ្ឌ៧។

## IV ឧទ្ធរណ៍របស់ភាគី

១៩. នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធការបន្តថិរវេលានៃការឃុំខ្លួនលើជនជាប់ចោទដែលបានសម្រេចនៅក្នុងដីកាដំណោះស្រាយ និងបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទ[១៥]។

២០. សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេត ពុំបានអនុវត្តតាមលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង ៦៨ ដែលថា ការបន្តឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទតទៅទៀត គួរត្រូវបានបង្គាប់តាមរយៈ "សេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយនៅក្នុងដីកានៅក្នុងដីកាដំណោះស្រាយ"។ សហមេធាវីការពារក្តីបញ្ជាក់អំពីចំនុចសង្ខេបនៅក្នុងផ្នែករបស់ដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងការបន្តការឃុំខ្លួន និងករណី ដែលផ្នែកនោះសំអាងទៅលើសំអាងហេតុមុនរបស់អង្គបុរេជំនុំជម្រះ។ សហមេធាវីការពារក្តីលើកឡើងថា អនុលោមតាមវិធានផ្ទៃក្នុង ៦៨ ប្រសិនបើពុំមានសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយទេ ការចេញដីកាដំណោះស្រាយគឺជាការបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន[១៦]។

២១. ម៉្យាងវិញទៀត សហមេធាវីការពារក្តីលើកឡើងថា ប្រសិនបើដីកាដំណោះស្រាយមានសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយ ដែលបង្គាប់ឲ្យបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទ សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការសម្រេចថា ការបន្តការឃុំខ្លួនគឺជាវិធានការចាំបាច់ដើម្បីធានានូវវត្តមានរបស់ជនជាប់ចោទនៅពេលជំនុំជម្រះ ដើម្បីការពារដល់សន្តិសុខរបស់គាត់ និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ[១៧]។

២២. ក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តយ៉ាងត្រឹមត្រូវនូវវិធានផ្ទៃក្នុង ៦៣ និង ៦៨ ក្នុងការបន្តការឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទ។ សហ

---

[១៥] បណ្តឹងឧទ្ធរណ៍ ផ្នែកទី IV។

[១៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១២។

[១៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៤-១៨។

ព្រះរាជអាជ្ញាលើកឡើងថា ដីកាដំណោះស្រាយមាន "សេចក្ដីសម្រេចដោយមានសំអាងហេតុជាក់លាក់មួយ" ដូចដែល វិធាន៦៨(១) បានតម្រូវឱ្យមាន ហើយថា ការឃុំខ្លួនជនជាប់ចោទបណ្ដោះអាសន្ន នៅតែជាការចាំបាច់[១៨]។ សហព្រះរាជអាជ្ញាលើកឡើងថា ជនជាប់ចោទខកខានមិនបានបង្ហាញពីការផ្លាស់ប្ដូរនៅក្នុងកាលៈទេសៈណាមួយ ដែលតម្រូវឱ្យពិនិត្យសារឡើងវិញពីភាពចាំបាច់នៃការឃុំខ្លួនគាត់ឡើយ[១៩]។

២៣. ក្នុងការឆ្លើយតប សហមេធាវីការពារក្ដីលើកឡើងថា ការសំអាងរបស់សហចៅក្រមស៊ើបអង្កេតទៅលើការសំអាងហេតុពីមុននៅក្នុងដីកាដំណោះស្រាយ គឺពុំមានលក្ខណៈគ្រប់គ្រាន់ឡើយក្នុងការបំពេញតាមលក្ខខណ្ឌដើម្បីចេញសេចក្ដីសម្រេចមានសំអាងហេតុ[២០]។ សហមេធាវីការពារក្ដីលើកឡើងផងដែរថា មេធាវីការពារក្ដីគ្មានបន្ទុកបង្ហាញភស្ដុតាងថា ជនជាប់ចោទគួរត្រូវតែបានដោះលែងឱ្យនៅក្រៅឃុំឡើយ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតត្រូវពិចារណាឱ្យបានដិតដល់ថាតើការបន្តការឃុំខ្លួនបណ្ដោះអាសន្ន (ដែលគួរតែតម្រូវឱ្យមានតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ) គឺត្រឹមត្រូវដែរឬទេ[២១]។

២៤. ដោយពិចារណាអំពីសេចក្ដីសម្រេចមុនៗរបស់ខ្លួន ទាក់ទិននឹងការឃុំខ្លួនបណ្ដោះអាសន្ន និងទឡ្ហីករណ៍របស់ភាគី អង្គបុរេជំនុំជម្រះនឹងពិនិត្យឡើងវិញលើការបន្តការឃុំខ្លួនបណ្ដោះអាសន្នលើ អៀង សារី ដែលសម្រេចនៅក្នុងដីកាដំណោះស្រាយ ដោយពិនិត្យទៅលើ ៖

ក. ថាតើសហចៅក្រមស៊ើបអង្កេតបានផ្ដល់ "សេចក្ដីសម្រេចមានសំអាងហេតុជាក់លាក់មួយនៅក្នុងដីកាដំណោះស្រាយ" ដែរឬទេ (វិធានផ្ទៃក្នុង ៦៨(១))។

ខ. មូលដ្ឋានដែលបញ្ជាក់ថាការឃុំខ្លួនជាវិធានការចាំបាច់មួយ(វិធានផ្ទៃក្នុង ៦៣(៣)(ខ)។ និង

គ. សំណើរបស់ជនជាប់ចោទស្នើសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ

---

[១៨] ចម្លើយតប កថាខណ្ឌ៤ និង៥។

[១៩] ចម្លើយតប កថាខណ្ឌ៩។

[២០] សំណើ និងការឆ្លើយតប កថាខណ្ឌ១។

[២១] សំណើ និងការឆ្លើយតប កថាខណ្ឌ២។

ឃុំខ្លួនក្នុងផ្ទះ។

## V សេចក្តីពិចារណា

## ក. លក្ខខណ្ឌតម្រូវនៃសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយ

២៥. វិធានផ្ទៃក្នុង ៦៨(១) ចែងអំពីអានុភាពនៃដីកាដំណោះស្រាយទៅលើការឃុំខ្លួនបណ្តោះអាសន្ន និងដំណាក់កាលដែលត្រូវអនុវត្ត ប្រសិនបើត្រូវបន្តការឃុំខ្លួន បន្ទាប់ពីមានដីកាដំណោះស្រាយ ៖

> ការចេញដីកាដំណោះស្រាយមានអានុភាពបញ្ចប់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននិងដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅពេលដែលរយៈពេលកំណត់នៅក្នុងការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់។ ប៉ុន្តែនៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា លក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ឬឱ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការក្រោមវិធាន ៦៣ និង ៦៥ នៅតែតម្រូវសហចៅក្រមស៊ើបអង្កេតអាចសម្រេចបន្តឃុំជនជាប់ចោទបណ្តោះអាសន្នតទៅទៀត ឬ រក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដែលនៅក្នុងសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក នៅក្នុងដីកាដំណោះស្រាយរហូតដល់ជនជាប់ចោទនេះត្រូវនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង។

២៦. អង្គបុរេជំនុំជម្រះរំលឹកថា វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង ចែងថា សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន បានតែក្នុងលក្ខខណ្ឌ "មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើនដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"។ អនុលោមតាមវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតប្រាកដជាពិចារណាផងដែរថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់។

២៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អង្គបុរេជំនុំជម្រះបានលើកឡើងកាលពីមុនថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចផ្តល់មូលហេតុនៅក្នុងសេចក្តីសម្រេច ដើម្បីផ្តល់យុត្តិកម្មចំពោះការបំពេញកិច្ចរបស់ខ្លួន[២២]។

---

[២២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/73 កថាខណ្ឌ៦៤។

២៨. ដីកាដំណោះស្រាយរួមបញ្ចូលនូវផ្នែកមួយដែលមានចំណងជើងថា "ការរក្សាការឃុំខ្លួនបណ្ដោះអាសន្នជនជាប់ចោទ"។ ក្រោមចំណងជើងនេះ កថាខណ្ឌ ១៦២២ និង ១៦២៣ នៃដីកាដំណោះស្រាយបានចែងដូចខាងក្រោម៖

> ១៦២២. យល់ឃើញថា ដោយផ្អែកលើបទចោទដែលមាននៅក្នុងដីកានេះ ក្នុងការផ្ដល់យុត្តិកម្មដល់ការបញ្ជូន នួន ជា អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន ទៅអង្គជំនុំជម្រះ លក្ខខណ្ឌដែលបានកំណត់ដោយវិធាន ៦៣(៣) (ក) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ។
>
> ១៦២៣. យល់ឃើញថា ទាក់ទិននឹងលក្ខខណ្ឌដែលតម្រូវដោយវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង សំអាងហេតុនៃដីកាសម្រេចបន្តការឃុំខ្លួនបណ្ដោះអាសន្ន នួន ជា ចុងក្រោយបង្អស់ (ដែលមិនត្រូវបានប្ដឹងឧទ្ធរណ៍) ហើយសាលដីកាចុងក្រោយរបស់អង្គបុរេជំនុំជម្រះ ដែលសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន នៅតែរក្សាតំលៃរបស់ខ្លួនដដែល ហើយចំនុចថ្មីដែលមានតែមួយគត់គឺ ការចោទប្រកាន់ទៅលើអ្នកទាំងនោះ ដែលនេះរឹតតែធ្វើសំអាងហេតុដែលមាននៅក្នុងដីកាកន្លងមកកាន់តែមានលក្ខណៈរឹងមាំ និងធ្វើឱ្យការឃុំខ្លួនរឹតតែមានភាពចាំបាច់ជាងពេលណាៗទាំងអស់។

២៩. កថាខណ្ឌ ១៦២៤ នៃដីកាដំណោះស្រាយចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា ៖

> ១៦២៤. ហេតុនេះ យល់ឃើញថា ការបន្តការឃុំខ្លួនជនជាប់ចោទរហូតដល់ពេលនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង ដោយអនុវត្តតាមវិធាន ៦៨ នៃវិធានផ្ទៃក្នុង គឺជាការចាំបាច់ដើម្បី៖
>
> (...)
>
> - ទាក់ទងនឹង អៀង សារី ដើម្បីធានាថា ជនជាប់ចោទនឹងមានវត្តមាននៅពេលជំនុំជម្រះ, ការពារសន្តិសុខដល់ជនជាប់ចោទ, រក្សាសណ្ដាប់ធ្នាប់សាធារណៈ ...

៣០. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានផ្ដល់សំអាងហេតុគ្រប់គ្រាន់សម្រាប់ការធ្វើសន្និដ្ឋានរបស់ខ្លួនដែលថា មាន "ហេតុផលដែលត្រូវបានរកឃើញ និងជាក់ជាក់យ៉ាងច្បាស់"។

៣១. ចំពោះលក្ខខណ្ឌកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតបានពិចារណាយ៉ាងច្បាស់ថា មានហេតុផលដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា អៀង សារី អាចប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម "ផ្អែកតាមភស្តុតាងដូចបានលើកឡើងនៅក្នុង" ដីកាដំណោះ



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00637139



ស្រាយ ដែលគាំទ្រចំពោះការចោទប្រកាន់បញ្ជូន អៀង សារី ទៅធ្វើការជំនុំជម្រះ[២៣]។ នៅពេលអានដីកាដំណោះស្រាយទាំងមូល ដីកានេះបានបង្ហាញអង្គហេតុ និងអង្គច្បាប់សំខាន់ៗយ៉ាងលម្អិតទាក់ទងនឹងជនជាប់ចោទ ដែលអង្គហេតុ និងអង្គច្បាប់ទាំងនេះគ្រប់គ្រាន់អាចផ្តល់ជា "មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់" ថា ជននេះអាចប្រព្រឹត្តបទល្មើសទាំងឡាយ ដូចបានបញ្ជាក់រួចហើយ។ សហចៅក្រមស៊ើបអង្កេតបានយកចំនុចនេះមកដាក់រួមបញ្ចូលដោយបន្ថែមលើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅក្នុងកថាខណ្ឌ ១៦២៣ នៃដីកាដំណោះស្រាយថា ការ ពិនិត្យលើឯកសារ និងភស្តុតាងទាំងឡាយនៅក្នុងសំណុំរឿងនៅក្នុងខែកុម្ភៈ ឆ្នាំ២០១០ បានធ្វើឱ្យខ្លួនសន្និដ្ឋានថា ភស្តុតាងទាំងអស់បានគាំទ្រចំពោះការសន្និដ្ឋានថា "មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់" មានអត្ថិភាពមែន។

៣២. វិធាន ៦៨ នៃវិធានផ្ទៃក្នុង មិនបានហាមឃាត់មិនឱ្យយកសំអាងហេតុជាក់លាក់មកដាក់បញ្ចូលតាមរយៈការយោងលើសេចក្តីសម្រេចមុនៗនោះទេ។ សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងកថាខណ្ឌ ១៦២៣ នៃដីកាដំណោះស្រាយ លើកឡើងអំពីភាពចាំបាច់ក្នុងការឃុំខ្លួនបណ្តោះអាសន្ន អនុលោមតាមវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងកថាខណ្ឌនេះថាតើមាន ឬ មានការផ្លាស់ប្តូរកាលៈទេសៈ ចាប់តាំងពីពេលអង្គបុរេជំនុំជម្រះចេញសាលដីកានៅក្នុងខែមេសា ឆ្នាំ២០១០ ដោយបានច្រានចោលបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្តឹងប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ("សាលដីកាខែមេសា ឆ្នាំ២០១០")[២៤]។ សហចៅក្រមស៊ើបអង្កេតបានពិចារណា និងបានបញ្ចូលសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅក្នុងសាលដីកាខែមេសា ឆ្នាំ២០១០ ហើយ បន្ទាប់មក ចង្អុលបញ្ជាក់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ជាធាតុថ្មីតែមួយគត់" បញ្ជាក់អំពីការផ្លាស់ប្តូរកាលៈទេសៈចាប់តាំងពីពេលចេញសាលដីកានេះ ដោយផ្តល់សំអាងហេតុថា ការផ្លាស់ប្តូរកាលៈទេសៈនេះ រឹតតែធ្វើឱ្យមានភាពចាំបាច់ក្នុងការឃុំខ្លួន អៀង សារី បណ្តោះអាសន្នថែមទៀត។ សំអាងហេតុនៅក្នុងសាលដីកាខែមេសា ឆ្នាំ២០១០

[២៣] ដីកាដំណោះស្រាយ កថាខណ្ឌ១៦២២។

[២៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ឯកសារ C22/9/14 ("សាលដីកាខែមេសា ឆ្នាំ២០១០")។

00637140



បានបញ្ជាក់យ៉ាងជាក់លាក់អំពីការឃុំខ្លួន អៀង សារី បណ្ដោះអាសន្ន ដោយសំអាងហេតុនេះត្រូវបានដាក់បញ្ចូលនៅក្នុងកថាខណ្ឌ ១៦២៣ នៃដីកាដំណោះស្រាយ ព្រមទាំងចង្អុលយោងលើដីកាបញ្ជូនជននេះទៅជំនុំជម្រះផងដែរ។

៣៣. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត មានលក្ខណៈជាក់លាក់ និងបានផ្ដល់សំអាងហេតុ ដូច្នេះ សេចក្ដីសម្រេចនេះធ្វើឡើងដោយគោរពទៅតាមវិធាន ៦៨(១) នៃវិធានផ្ទៃក្នុង។

**ខ. មូលដ្ឋាននានាឡាយ ដែលធ្វើឱ្យការឃុំខ្លួនជាវិធានការចាំបាច់**

៣៤. គោលការណ៍ទូទៅនោះគឺ ជនណាម្នាក់ មិនត្រូវបានគេឃុំខ្លួនជាបណ្ដោះអាសន្នឡើយ ក៏ប៉ុន្តែការឃុំខ្លួនបណ្ដោះអាសន្នគឺជាអញ្ញត្រកម្មចំពោះសិទ្ធិមានសេរីភាព។

**ភាពចាំបាច់នៅក្នុងការធានាវត្តមានជនជាប់ចោទនៅក្នុងការជំនុំជម្រះ**

៣៥. សហមេធាវីការពារក្ដីសន្និដ្ឋានថា ជនជាប់ចោទមានវ័យ ៨៦ ឆ្នាំ ហើយមានបញ្ហាផ្នែកសុខភាពដែលកម្រិតចំពោះការធ្វើបំលាស់ទីរបស់ជននេះ[២៥]។ សហមេធាវីការពារក្ដីសន្និដ្ឋានបន្ថែមទៀតថា ប្រសិនបើដោះលែងឱ្យមានសេរីភាពមែននោះ ជនជាប់ចោទនឹងមកសួរសុខទុក្ខភរិយារបស់ខ្លួន អៀង ធីរិទ្ធ ជារឿយៗ ដែលកំពុងស្ថិតនៅជាប់ឃុំខ្លួនបណ្ដោះអាសន្ន ហើយជនជាប់ចោទ "ពិបាកនឹងរំពឹងគិតថានឹងរត់គេចខ្លួនចេញពីប្រទេស ចាកចោលភរិយារបស់ខ្លួនណាស់"[២៦]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ខ្លួនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍ដូចគ្នានេះលើបញ្ហាវ័យ និងសុខភាពរបស់ជនជាប់ចោទ នៅក្នុងបណ្ដឹងឧទ្ធរណ៍មុនៗប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន[២៧] ហើយដូចបាន

---

[២៥] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១៥។

[២៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១៥។

[២៧] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ឯកសារ C22/9/14 កថាខណ្ឌ៣៨។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ C22/5/38, កថាខណ្ឌ២៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C

សន្និដ្ឋានដោយសហព្រះរាជអាជ្ញា[២៨] សហមេធាវីការពារក្ដីមិនបានផ្ដល់ភស្តុតាងណាមួយបង្ហាញថា ជនជាប់ចោទអាចនឹងមិនរត់គេចខ្លួនចេញពីប្រទេសនេះ តាមមធ្យោបាយធ្វើដំណើរណាមួយឡើយ។

៣៦. ហានិយភ័យនៃការរត់គេចខ្លួនរបស់ជនជាប់ចោទ មានការកើនឡើង ក្រោយពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយហេតុថា ជនជាប់ចោទរូបនេះនឹងប្រឈមនឹងការជំនុំជម្រះនាពេលឆាប់ៗនេះ ជាជាងលទ្ធភាពថានឹងអាចត្រូវបានជំនុំជម្រះនាពេលអនាគត។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់នាពេលមុនរួចហើយថា ក្នុងករណីជាប់ទោស ជនជាប់ចោទអាចត្រូវបានដាក់ពន្ធនាគាររយៈពេលចាប់ពី ៥ ឆ្នាំ ទៅមួយជីវិត ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃបទចោទដាក់បន្ទុកលើជននេះ[២៩]។

**ភាពចាំបាច់នៅក្នុងការការពារសន្តិសុខរបស់ជនជាប់ចោទ**

៣៧. សហមេធាវីការពារក្ដីជនជាប់ចោទ មិនបានផ្ដល់សេចក្ដីសន្និដ្ឋានណាមួយថ្មី ឬ បន្ថែម បង្ហាញថាមានការផ្លាស់ប្ដូរកាលៈទេសៈ ចាប់តាំងពីអង្គបុរេជំនុំជម្រះចេញសាលដីកាខែមេសា ឆ្នាំ២០១០ ដោយបានរកឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ននៅតែជាវិធានការចាំបាច់ដើម្បីការពារសន្តិសុខរបស់ជនជាប់ចោទ។

**ភាពចាំបាច់ក្នុងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ**

៣៨. សហមេធាវីការពារក្ដីសន្និដ្ឋានថា ចាប់តាំងពីដាក់ទោស ឌុច និងចោទប្រកាន់បញ្ជូន អៀង សារី នួន ជា អៀង ធីរិទ្ធ និងខៀវ សំផន ទៅជំនុំជម្រះមក ស្ថានភាពមានការផ្លាស់ប្ដូរ។ ការចោទប្រកាន់បញ្ជូនជនជាប់ចោទទៅជំនុំជម្រះ នាំឱ្យមានការសន្និដ្ឋានមួយថា នាពេលនេះ សាធារណៈជនមានការកាន់តែចាប់អារម្មណ៍ ឬ ខ្វាយខ្វល់នឹងហេតុការណ៍កើតឡើងនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។ ការពិចារណាដូច្នេះវាប៉ះពាល់នឹងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ ជាការចាំបាច់នៅ

---

[២៨] ចម្លើយតប កថាខណ្ឌ៩។

[២៩] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ឯកសារ C22/9/14 កថាខណ្ឌ៤២។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ក្នុងការរក្សាជនជាប់ចោទនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។ មិនតែប៉ុណ្ណោះ សណ្ដាប់ធ្នាប់សាធារណៈអាចគម្រាមកំហែងដល់សន្តិសុខរបស់ជនជាប់ចោទ។

**គ. សំណើសុំឱ្យឃុំខ្លួនក្នុងផ្ទះ**

៣៩. សហមេធាវីការពារក្ដីស្នើសុំឱ្យបង្គាប់វិធានការដែលមានលក្ខណៈធូរស្រាលជាងការឃុំខ្លួនបណ្ដោះអាសន្ន ពោលគឺរួមទាំង ការឃុំខ្លួនក្នុងផ្ទះផងដែរ[៣០]។ អង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងសាលដីកា ខែមេសា ឆ្នាំ២០១០ របស់ខ្លួន លើសំណើសុំឱ្យឃុំខ្លួនក្នុងផ្ទះរួចហើយ ដោយរកឃើញថាភាពចាំបាច់ក្នុងការឃុំខ្លួនជននេះបណ្ដោះអាសន្ន មានលក្ខណៈចាំបាច់ជាងការឃុំខ្លួនក្នុងផ្ទះ[៣១]។ សហមេធាវីមិនបានផ្ដល់ហេតុផលឱ្យអង្គបុរេជំនុំជម្រះ ងាកចេញពីសេចក្ដីសម្រេចមុនៗរបស់ខ្លួនលើបញ្ហានេះឡើយ។

៤០. ដោយមានសំអាងហេតុដូចបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះសម្រេចដូចនឹងសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ ដែលបានប្រកាសនាថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០[៣២]។

ភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១

**អង្គបុរេជំនុំជម្រះ**

Rowan DOWNING ន័យ ថុល Catherine MARCHI-UHEL ហួត វុទ្ធី ប្រាក់ គឹមសាន

[៣០] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១៦។

[៣១] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ឯកសារ C22/9/14 កថាខណ្ឌ កថាខណ្ឌ៦៣-៤។

[៣២] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/5/9។